យើងមិនគ្រាន់តែត្រូវការគំនិតរឹងប៉ឹងក្នុងការជួយយើងឲ្យចេះជ្រើសរើសយកជំនឿគ្រីស្តបរិស័ទ ឬ ជំនឿអ្វីមួយផ្សេងទៀតតែប៉ុណ្ណោះទេ។ ក្រោយពីយើងបានក្លាយជាគ្រីស្តបរិស័ទហើយ យើងក៏ត្រូវការបែងចែកឲ្យដឹងថាក្រុមណាមួយជាក្រុមគ្រីស្តបរិស័ទពិតប្រាកដត្រឹមត្រូវតាម បទគម្ពីរ និងក្រុមណាជាក្រុមដែលអះអាងថាខ្លួនជាគ្រីស្តបរិស័ទតែយល់ច្រឡំប្រើប្រាស់ព្រះគម្ពីរមិនបានត្រឹមត្រូវ ។ សាវ័កយ៉ូហានបានព្រមានអ្នកអានសំបុត្ររបស់គាត់ថា ៖" សូមកុំជឿអស់អ្នកដែលថាខ្លួនមានព្រះវិញ្ញាណគង់នៅជាមួយនោះឡើយ ត្រូវល្បងលមើលដើម្បីឲ្យដឹងថាវិញ្ញាណនេះមកពីព្រះជាម្ចាស់មែន ឬ យ៉ាងណា ដ្បិតមានព្យាការីក្លែងក្លាយជាច្រើនបានមកក្នុងលោកនេះ[២] ។ គ្រីស្តបរិស័ទអាចនឹងមានគ្រោះថ្នាក់ដោយ" លះបង់ចិត្ត ស្មោះសរ និង ចិត្តបរិសុទ្ធចំពោះព្រះគ្រីស្ត" ហើយទៅដើរតាម" ព្រះយេស៊ូណាមួយផ្សេងទៀតក្រៅពីព្រះយេស៊ូដែលយើង ( ពួកសាវ័ក ) ប្រកាសនោះ[៣] ឬ ងាកចេញពី "ព្រះជាម្ចាស់ដែលបានត្រាស់ហៅបងប្អូនមកតាមព្រះគុណរបស់ព្រះគ្រីស្ត

---

[១] *កិច្ចការ ១៧:១០-១៥*

[២] *យ៉ូហាន ៤:១*

[៣] *២កូរិនថូស ១១: ៣-៤*

ហើយបែរទៅរកដំណឹងល្អមួយផ្សេងទៀតដែលមិនមែនជាដំណឹងល្អទាល់តែសោះ"[៤] ។ គ្រីស្ទបរិស័ទ ត្រូវតែឈប់គិតតាមរបៀបកូនក្មេងទៀតគឺត្រូវគិតតាមរបៀបមនុស្សចាស់វិញ[៥] ។

សមត្ថភាពក្នុងការមើលឲ្យឃើញភាពខុសប្លែកគ្នារវាងសេចក្តីពិត និង សេចក្តីខុសឆ្គង ឬ មួយណាល្អជាងមួយណាល្អដាច់គេ មិនមែនចេះកើតឡើងចំពោះយើងភ្លាមមួយរំពេច ហើយកើតឡើងតែម្តងជាសំរេចនោះទេ។ តែការនេះច្រើនតែកើតឡើងជាបន្តបន្ទាប់ហើយកាន់តែដុះខាត់យើងឲ្យភ្លឺថ្លាឡើងអស់មួយជីវិតយើងមិនថាយើងជាបុគ្គលម្នាក់ ដាច់ដោយឡែកមិនថាយើងរួមគ្នាជាក្រុមជំនុំនោះឡើយ។ ដោយហេតុថា ដូច្នេះបានជាលោកប៉ូលអធិស្ឋានឲ្យក្រុមជំនុំនៅក្រុងភីលីព" មានសេចក្តីស្រឡាញ់ដ៏លើសលប់កាន់តែខ្លាំងឡើងៗធ្វើឲ្យគេចេះដឹងច្បាស់ និង យល់សព្វគ្រប់ទាំងអស់"[៦]។ នៅក្នុងខគម្ពីរនេះ ការសង្កេតស្គាល់មានន័យថាជាការជ្រើសរើសយកអ្វីដែលល្អបំផុតនៅពេលដែលយើងមានអ្វីៗដែលល្អជាច្រើនសំរាប់ជ្រើសរើស ប៉ុន្តែមានមួយដែលល្អដាច់គេសំរាប់ឲ្យយើងជ្រើសរើស។ ក្នុងករណីបែបនេះ យើងចាំបាច់ត្រូវតែនិយាយថា "ទេ" ចំពោះអ្វីណាដែលគ្រាន់តែល្អហើយ និយាយថា"បាទ ឬ ចាស" ចំពោះអ្វីណាដែលល្អដាច់គេ ។ ចំណុចដែលខ្ញុំចង់លើកមកបង្ហាញនៅពេលនេះគឺជំនឿគ្រីស្ទបរិស័ទហៅយើងឲ្យមានកំឡាំងនៃគំនិតជាច្រើនបែបច្រើនយ៉ាងដើម្បីសង្កេតឲ្យស្គាល់សេចក្តីពិតជំនឿគ្រីស្ទបរិស័ទមិន ចេះតែធ្វើពើជាអ្វីៗទាំងអស់សុទ្ធតែស្មើគ្នានោះឡើយ។

---

[៤] *កាឡាទី ១ :៦-៧*

[៥] *១ កូរិនថូស ១៤:២០*

[៦] *ភីលីព ១:៩*

ភាពដាច់ខាត

ក្រោយពីយើងរកឃើញថាអ្វីជាសេចក្តីពិតរួចហើយ ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យឲ្យគ្រីស្ទបរិស័ទដាក់ចិត្តតែពាក់កណ្តាលចំពោះសេចក្តីពិតនោះឡើយ ។ ព្រះគម្ពីរពឹងលើយើងដែលចេះប្តូរផ្តាច់យ៉ាងរឹងប៉ឹង យ៉ាងម៉ឹងម៉ាត់ និងយ៉ាងច្បាស់លាស់ ។ ជំនឿគ្រីស្ទបរិស័ទដែលស្របតាម បទគម្ពីរមិនមែនជាជំនឿម៉ាៗយកសឹងនោះទេ។

បទគម្ពីរខ្លះទៀតឲ្យយោបល់យើងថា ព្រះចង់បានគ្រីស្ទបរិស័ទដែលរឹងប៉ឹងក្នុងការប្តូរផ្តាច់ ( ទោះបីពេលខ្លះការប្តូរផ្តាច់នោះអាចខុសឆ្គងក៏ដោយ )ជាជាងគ្រីស្ទបរិស័ទដែលមិនចេះអារកាត់ ។ យ៉ូស្វេចង់ឲ្យជនជាតិអ៊ីស្រាអែលជ្រើសរើសយកព្រះណាមួយជាជាងអត់ព្រះ ទោះបីព្រះនោះមិនមែនជាព្រះយេហូវ៉ាក៏ដោយ [៧] ។ លោកអេលីយ៉ាជំរុញជនជាតិអ៊ីស្រាអែលដែលស្ទើរស្ទាក់ឲ្យគោរពបំរើព្រះបាល បើព្រះបាលនោះជាព្រះយ៉ាងពិតប្រាកដមែនប្រសើរជាងនៅរារែកអល់អែកមិនចេះធ្វើការអារកាត់អ្វីទាល់តែសោះ[៨] ។ ព្រះយេស៊ូប្រាថ្នាចង់ឃើញក្រុមជំនុំនៅក្រុងឡៅឌីសេមានចិត្តក្តៅគគុក ឬ ត្រជាក់ស្របប្រសើរជាងក្តៅឧណ្ហៗ [៩] ។ បើការរស់ឡើងវិញរបស់យើងមិនអាចក្លាយទៅជាការពិតទេយើងគួរតែ" ស៊ីផឹកអ្វីបានតាមចិត្តព្រោះគង់តែស្លាប់នៅថ្ងៃស្អែកដដែល"[១០] ។ បើយើងចង់រស់មានន័យមានខ្លឹមសារសំរាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់យើងត្រូវតែ "លះបង់ខ្លួនឯង លះបង់សាច់ញាតិស្និទ្ធស្នាលគ្រប់ចិត្តលី

[៧] យ៉ូស្វេ ២៤:១៤-១៥
[៨] ១ ពង្សាវតារ ១៨:២១
[៩] វិវរណៈ ៣:១៥
[៧] យ៉ូស្វេ ២៤:១៤-១៥
[៨] ១ ពង្សាវតារ ១៨:២១
[៩] វិវរណៈ ៣ :១៥
[១០] ១ កូរិនថូស ១៥: ៣០

ឈើឆ្កាង ហើយដើរតាមព្រះគ្រីស្ទ"[១១]។ ភាពមានន័យមិនដែលកើតឡើងចំពោះព្រលឹងដែលមិនចេះអារកាត់គឺអ្នក ដែលដៃចាប់កាន់យាមនង្គ័លហើយភ្នែកចេះតែសំឡឹងមើលក្រោយ[១២]។ ការធ្វើជាគ្រីស្ទបរិស័ទមែន មិនមែនធ្វើជាគ្រីស្ទបរិស័ទផងថ្វាយបង្គំអារុក្ខអារក្ខ អ្នកតាផង ឬ ថ្វាយបង្គំព្រះពុទ្ធផងក្នុងពេលជាមួយគ្នានោះទេ។

---

*[១១] លូកា ៩:២៣-២៧ ;១៤:២៦ -២៧ ពាក្យ "ស្រឡាញ់ "និង "ស្អប់" ជូនកាលត្រូវគេប្រើនៅក្នុងព្រះគម្ពីរមិនមែន ដើម្បីបកស្រាយពី អារម្មណ៍ស្រឡាញ់ពេញចិត្ត ឬ ស្អប់ខ្ពើមនោះឡើយ ប៉ុន្តែជាសញ្ញាមិនលំអៀងនៃការ "ជ្រើសរើស ឬ បដិសេធ ។ ដូច្នេះក្នុងម៉ាឡាគី ១:២-៥ ព្រះជាម្ចាស់ " ស្រឡាញ់ " យ៉ាកុបតែព្រះអង្គ "ស្អប់ " អេសាវ គឺមានន័យដូច្នេះឯង ។ រឿងនេះជារឿងដែលហាក់ដូចជាពាក់ព័ន្ធដល់ការជ្រើសរើសច្រើនជាងរឿងនៃមនោសញ្ចេតនា ។ លោកប៉ូលបានបញ្ជាក់ពីរឿងនេះយ៉ាងច្បាស់នៅក្នុងរ៉ូម៩:១០-១៣ ថា មុនពេលដែលកូនភ្លោះទាំងប្រសូតចេញមក "ព្រះជាម្ចាស់មានគំរោងការជ្រើសរើសមនុស្សដោយមិនគិតពីអំពើ ដែលគេប្រព្រឹត្តនោះទេគឺ ជ្រើសរើសតាមព្រះហឫទ័យរបស់ព្រះអង្គដែលត្រាស់ហៅ ។ ដើម្បីឲ្យបានស្របតាមគំរោងការ នេះ នៅពេលកូនភ្លោះ នៅក្នុងផ្ទៃពុំទាន់បានប្រព្រឹត្តអំពើ ល្អ ឬ អាក្រក់នៅឡើយផងនោះ ។ ទ្រង់ក៏មានព្រះបន្ទូលទៅនាង រេបេកាថា កូនច្បង នឹងបំរើកូនប្អូន" ដូចមានចែងទុកមកពី " យើងស្រឡាញ់យ៉ាកុបជាងអេសាវ " ( មានន័យថា បដិសេធ ចេញពីភាពជាដៃគូ ក្នុងសម្ពន្ធមេត្រី ) ។ ដូចគ្នាដែរព្រះយេស៊ូ មិនបានលើកទឹកចិត្តសាវ័កព្រះអង្គឲ្យស្រឡាញ់លុយឡើយ ។ សុភាសិតក៏មាននិយាយជាពិសេសអំពីតម្លៃនៃរឿងនេះដែរ ។ ដោយហេតុថាយើងមិនអាចបំរើចៅហ្វាយពីរបានយើងមុខជាស្អប់មួយ ( បដិសេធមិនបំរើ ) និងស្រឡាញ់មួយ ( ជ្រើសរើសបំរើ ) វិញ ។ ក្នុងលូកាពាក្យ "ស្អប់ " មិនមានន័យជាមនោ សញ្ចេតនាស្អប់ខ្ពើមយ៉ាងខ្លាំង ចំពោះឪពុកម្ដាយរបស់យើងនោះទេ ដើម្បីកុំឲ្យប្រទាញ ប្រទង់នឹងបទគម្ពីរផ្សេងទៀតដែលបង្គាប់ឲ្យយើងគោរពឪពុកម្ដាយ ។ លះបង់ ឬ លះអាល័យពី ឪពុកម្ដាយ គឺមិនធ្វើតាមចិត្តគាត់ដែលជំទាស់យើងមិនឲ្យដើរតាមព្រះគ្រីស្ទតែប៉ុណ្ណោះ។*

*[១២] លូកា ៩:៦២*

## ការប្រព្រឹត្ត

ក្រោយពីបានប្រើប្រាស់កំឡាំងដ៏សំខាន់នៃគំនិត ដើម្បីសង្កេតឲ្យស្គាល់សេចក្ដីពិត និងកំឡាំងដាច់ណាត់នៃឆន្ទៈ ក្នុងការកាន់តាមសេចក្ដីពិតនេះគ្រីស្ទបរិស័ទត្រូវ បានទទួលការជំរុញចិត្តឲ្យបង្ហាញកំឡាំងសកម្មនៃការប្រព្រឹត្ត។ គ្រីស្ទបរិស័ទត្រូវតែរស់ដើម្បីសេចក្ដីពិត។

ទីមួយ រឿងនេះជារឿងពិតសំរាប់ជីវិតមនុស្សទូទៅ ។ ប៉ុន្តែព្រះគម្ពីរទាមទារជាពិសេសឲ្យសហគមន៍គ្រីស្ទបរិស័ទក្រោកឈរឡើងជំទាស់នឹងទស្សនៈមិនត្រឹមត្រូវរបស់សាសនា ។រឹងប៉ឹងក្នុងសេចក្ដីពិតរាប់បញ្ចូលទាំងភាពរឹងប៉ឹងប្រឆាំងនឹងការមិនត្រឹមត្រូវ ។ ពេលដែលជនជាតិយូដាខ្លះព្យាយាមចង់បង្ខិតបង្ខំគ្រីស្ទបរិស័ទសាសន៍ដទៃឲ្យទទួលពិធីកាត់ស្បែក ហើយគោរពតាមក្រឹត្យវិន័យក្នុងគម្ពីរសម្ពន្ធមេត្រីចាស់នោះ លោកប៉ូល និង លោកបាណាបាស ប្រកែកប្រណាំងគ្នាយ៉ាងតឹងសសៃក[13] ។ ការបង្រៀនខុសឆ្គងរបស់ជនជាតិយូដាកកូរកកាយចិត្តរបស់ពួកសាវ័កឲ្យចាំបាច់ត្រូវតែបង្ហាញជាបន្ទាន់ឲ្យពួកយូដាឃើញថាការបង្រៀននោះមិនមែនខុសឆ្គងដោយសារវាគ្រាន់តែជា គំនិតខុសប្លែកគ្នាដោយគ្មានកំហុស ចំពោះរឿងមួយដែលពុំសូវជាសំខាន់ប៉ុន្មាននោះទេ គឺជំនឿនោះអាចនឹង បំផ្លាញជំនឿរបស់បុគ្គលម្នាក់ៗ ឬក្រុមគ្រួសារគាត់ទាំងមូលបាន[14]។ មានតែត្រូវឃ្លាំពិនិត្យមើលគោលលិទ្ធិរបស់ខ្លួនឲ្យបានជិតដល់នោះទេទើបអ្នកបំរើរបស់ព្រះអម្ចាស់អាចសង្គ្រោះទាំងខ្លួនឯងផង និងទាំងមជ្ឈដ្ឋានអ្នកស្ដាប់របស់ខ្លួនផងបាន[15]។ អ្នកដឹកនាំក្រុមជំនុំជំនាន់ដើមជាបន្តបន្ទាប់ហាក់ដូចជាមិនសូវជាស្វាគមន៍គោលលិទ្ធិ និង ការប្រតិបត្តិជំនឿខុសឆ្គងប៉ុន្មានទេ ប៉ុន្តែពួកគាត់ជំទាស់ប្រឆាំងនឹងការទាំងអស់នេះ

---

[13] *កិច្ចការ ១៥:២*

[14] *២ ធីម៉ូថេ ២:១៨; ទីតុស ១:១១*

[15] *១ ធីម៉ូថេ ៤:១៦*

យ៉ាងខ្លាំងក្លា គឺហ៊ានរហូតដល់ថ្នាក់ជំទាស់ប្រឆាំងចំពោះអគ្គសាវ័កពេត្រុស ទៀតផង[១៦]។ ព្រះអម្ចាស់ដែលទទួលការតម្កើង សិរីរុងរឿងសរសើរក្រុមជំនុំក្រុងអេភេសូ ដែលហ៊ានជំទាស់ប្រឆាំងចំពោះសាវ័កក្លែងក្លាយ តែផ្ទុយទៅវិញ ព្រះអង្គបន្ទោសក្រុមជំនុំក្រុងពើកាម៉ុស ដែលបើកឲ្យគ្រូដែលប្រកាន់ទស្សនៈ តាមសេចក្ដីបង្រៀនរបស់បាឡាម និង នីកូឡាស ចូលមកបង្រៀន ។ ព្រះអង្គក៏បន្ទោសក្រុមជំនុំក្រុងធាតេរ៉ា ដែលអនុគ្រោះព្យាការីនីម្នាក់ដែលហៅខ្លួនឯងថា យេសេបិលទៀតផង[១៧]។ ការបែកចេញពីគោលលិទ្ធិដែលត្រឹមត្រូវពិតប្រាកដអាចនាំឲ្យយើងបាត់វង្វាន់រីឯការបើកទ្វារឲ្យគេចូលមកបង្រៀនគោលលិទ្ធិមិនត្រឹមត្រូវ គឺជាការចូលដៃចូលជើងក្នុងការអាក្រក់របស់ពួកគេ [១៨]។ អ្នកដឹកនាំក្រុមជំនុំជំនាន់ដើមបង្ខំចិត្តជំរុញគ្រីស្ទបរិស័ទដែលដើរតាមខ្លួនឲ្យ" តយុទ្ធការពារជំនឿដែលព្រះជាម្ចាស់បានប្រទានដល់ប្រជាជនដ៏វិសុទ្ធម្ដងជាសូរេច" [១៩]។

និយាយឲ្យខ្លីទៅគឺថា៖ សេចក្ដីពិត និង សេចក្ដីខុសឆ្គងនៅក្នុងសេចក្ដីបង្រៀនទាំងឡាយផ្នែកសាសនានោះគឺជាបញ្ហាសំខាន់ ។ គ្រីស្ទបរិស័ទដែលដើរតាមគំរូរបស់ព្រះគម្ពីរគឺត្រូវតែមានគំនិតរឹងប៉ឹងដើម្បីសង្កេតមើលដឹងពីសេចក្ដីពិតមានឆន្ទៈរឹងប៉ឹងដើម្បីចិត្តប្ដេជ្ញាចិត្តយ៉ាងមុតមាំចំពោះជំនឿ និង មានភាពរឹងប៉ឹងក្នុងការប្រព្រឹត្តិដើម្បីលើកស្ទួយសេចក្ដីពិត និង ហ៊ានតតាំងចំពោះសេចក្ដីខុសឆ្គង ។ បុរសខ្លាំងតាមពិតទៅបង្ហាញចំណុចខ្លាំងរបស់ខ្លួននៅក្នុងផ្នែកមួយនៃការដឹកនាំ និង ពន្ធកិច្ចរបស់គ្រីស្ទបរិស័ទ។

---

[១៦] *កាឡាទី ២:១១-២១*

[១៧] *វិវរណៈ ២: ២; ២០*

[១៨] *២ យ៉ូហាន ៧-១១*

[១៩] *យូដាស ៣*

## ព័ន្ធការីគ្រីស្ទបរិស័ទៈ ទន់ភ្លន់ជាមួយមនុស្សទូទៅ

ប៉ុន្តែតើបុរសខ្លាំងត្រូវខ្លាំងតាំងពីដើមដល់ចប់ឬ ? ជាពិសេសតើយើងត្រូវបង្ហាញពីកម្លាំងរបស់យើងដោយរបៀបណា ? ព័ន្ធការីជាគ្រីស្ទបរិស័ទត្រូវតែរឹងប៉ឹងចំពោះសេចក្ដីពិតជានិច្ច ។ ប៉ុន្តែតើឥរិយាបទរបស់គាត់ត្រូវតែដូចមនុស្សទូទៅឬ ?

### គំរូជាទូទៅ

គំរូជាទូទៅគឺភាពទន់ភ្លន់ ។ គឺទន់ភ្លន់ទាំងនៅក្នុងការបញ្ជា និង ក្នុងគំរូផ្ទាល់នៃការដោះស្រាយបញ្ហាផ្សេងៗនៅក្នុងគម្ពីរសញ្ញាថ្មីបានជំរុញលើកទឹកចិត្តឲ្យយើងប្រើភាពទន់ភ្លន់ ជាមធ្យោបាយបង្កើបប្រាប់ពីសេចក្ដី ពិត និង បង្ហាញពីភាពខុសឆ្គង ។ បទគម្ពីរមិនបានលើកទឹកចិត្តយើងមានអំនួត និង ប្រើមធ្យោបាយវាយប្រហារនៅពេលដែលយើងផ្សាយដំណឹងល្អនោះឡើយ។

*២ ធីម៉ូថេ ២:២៣-២៦* ។២ ធីម៉ូថេនេះប្រហែលជាសំបុត្រចុងក្រោយរបស់សាវ័កប៉ូល។ នៅក្នុងសំបុត្រនោះលោកបានបង្រៀនដល់ពួក សិស្សរបស់លោកពីរបៀបដែលពួកគេត្រូវបន្តការងារបំរើព្រះបន្តទៅទៀត បន្ទាប់ពីពេលដែលការងាររបស់លោកត្រូវបានបញ្ចប់ទៅនោះ ។ សំបុត្រនោះបានបង្ហាញពីគំរូនៃការបញ្ចូលកម្លាំងរឹងប៉ឹងក្នុងសេចក្ដីពិត និងមានចិត្តទន់ភ្លន់ចំពោះមនុស្សទូទៅ ។

នៅអត្ថបទនៃព្រះគម្ពីរត្រង់នេះ យើងឃើញគំរូភាពរឹងប៉ឹងនៃសេចក្ដីពិតបានផុសឡើងនៅពេលដែលលោកប៉ូលមានប្រសាសន៍ថា ព្រះជាម្ចាស់មិនបានប្រទានឲ្យយើងមានវិញ្ញាណដែលនាំឲ្យខ្លាចទេ ។ ហេតុដូច្នេះធីម៉ូថេមិនត្រូវខ្មាសមិនហ៊ាននិយាយពីព្រះអម្ចាស់ឡើយ តែត្រូវតែរឹងប៉ឹងឡើង

ដើម្បីចូលរួមរងការឈឺចាប់ជាមួយលោកប៉ូលក្នុងបុព្វហេតុនៃដំណឹងល្អ [២០]។ គាត់ត្រូវតែរក្សាឲ្យបានខ្ជាប់ខ្ជួននូវសេចក្តីបង្រៀនដ៏ល្អនេះ និង រក្សាទុកឲ្យបានគង់វង្សនូវអ្វីដែលបានផ្ញើទុកនឹងគាត់ [២១]។ រីឯប៉ុងនៅក្នុងព្រះគុណព្រះធីម៉ូថេត្រូវហុចបន្តនូវជំនឿគ្រីស្ទបរិស័ទដល់អ្នកដទៃ[២២]។ ដោយទទួលខុសត្រូវក្នុងការហុចបន្តដោយត្រឹមត្រូវ[២៣]។ ការផ្តល់គំនិតរបស់គាត់ដោយយកចិត្តទុកដាក់ទៅនឹងសេចក្តីបង្រៀនដ៏ល្អត្រឹមត្រូវគាត់ត្រូវជៀសវាងពីការជជែកវែកញែកដ៏ល្ងីល្ងើផ្តេសផ្តាស[២៤] ។

ប៉ុន្តែតើធីម៉ូថេត្រូវបន្តព័ន្ធកិច្ចនៃការរឹងប៉ឹងចំពោះសេចក្តីពិត នោះដោយរបៀបណា ?

> រីឯអ្នកបំរើរបស់ព្រះអម្ចាស់មិនត្រូវឲ្យការឈ្លោះប្រកែកគ្នាឡើយ ផ្ទុយទៅវិញត្រូវរួសរាយចំពោះមនុស្សទូទៅត្រូវចេះបង្រៀន និង អធ្យាស្រ័យដល់គេត្រូវមានចិត្តស្លូតបូតប្រដៅពួកអ្នកប្រឆាំងក្រែងលោព្រះជាម្ចាស់នឹងប្រោសប្រទានឲ្យគេកែប្រែចិត្តគំនិតដើម្បីឲ្យគេបានស្គាល់ សេចក្តីពិតយ៉ាងច្បាស់ព្រម ទាំងភ្ញាក់ស្មារតីឡើងវិញ ហើយដោះខ្លួនរួចពីអន្ទាក់របស់មារដែលបានចាប់ចងគេបង្ខំឲ្យ ធ្វើតាមបំណងរបស់វា [២៥] ។

ភាសាក្រិកពាក្យបកប្រែ "ឈ្លោះ" មានន័យថាដំបូងឈ្លោះដោយប្រើរូបកាយហើយក្រោយមកប្រើសំដីរបស់យើងគឺ ៖ *ឈ្លោះទាស់ទែងប្រកែក ប្រណាំង*

---

[២០] *២ ធីម៉ូថេ ១:៧-៨*

[២១] *២ ធីម៉ូថេ ១:១៣-១៤*

[២២] *២ ធីម៉ូថេ ២:១-២ ; ១៤*

[២៣] *២ ធីម៉ូថេ ២:១៥*

[២៤] *២ ធីម៉ូថេ ២:១៤; ១៦; ២៣*

[២៥] *២ ធីម៉ូថេ ២:២៤ -២៦*

*គ្នា* ។ ហេតុដូច្នេះហើយគឺមានន័យធ្ងន់ធ្ងរចំពោះពាក្យ" ទំនាស់" គឺមានការឈឺចុកចាប់ និង ជូរចត់យ៉ាងខ្លាំង ។ អ្នកបំរើព្រះអម្ចាស់មិនត្រូវជាប់ជំពាក់ក្នុងរឿងទាស់ទែងបែបនោះឡើយ ។ តែត្រូវឲ្យមានចិត្ត"សប្បុរស" ដែលជាពាក្យជាភាសាក្រិកក្នុងគម្ពីរសញ្ញាថ្មីប្រើដើម្បីពណ៌នាពីរបៀបដែលម្ដាយមើលថែកូនតូចរបស់ខ្លួន [២៦] ។ ម្ដាយមិនរហ័សខឹងជាមួយកូនៗឡើយ តែមានចិត្តអំណត់ និង លួងលោមកូន សូម្បីតែនៅពេលដែលគាត់ត្រូវព្យាយាមបង្រៀនអ្វីមួយឲ្យកូនបានដឹង ឬ ត្រូវប្រដៅតម្រង់ ។ ត្រង់នេះបង្ហាញពីរូបភាពដែលគិលានុបដ្ឋាយិកា លួងលោមដល់អ្នកជម្ងឺវ័យក្មេង មិនមែនមានលក្ខណៈដូចបុរសខ្លាំងកំពុងលើកដុំដែកតម្លើងសាច់ដុំនោះឡើយ ម្ដាយប្រព្រឹត្តនឹងកូនបែបនោះទើបសមរម្យ ។ លើសពីនេះទៅទៀតព័ន្ធការីគ្រីស្ទបរិស័ទមិនត្រូវ "ច្រលោតខឹង" មានន័យថា*អាចអត់ទ្រាំនឹងទុក្ខលំបាកដោយមិនខឹង ឬ មួម៉ៅឡើយ* ។ ការមិនច្រឡោតខឹងអ្នកបំរើព្រះដ៏រឹងមាំនៅក្នុងបទគម្ពីរ បានបង្រៀនដោយសុភាពទន់ភ្លន់ដល់អ្នកដែលប្រឆាំងជាមួយគាត់ ។ ពាក្យ" សុភាពទន់ភ្លន់" មានន័យថា មាន*ឥរិយាបទទន់ភ្លន់ និង អាកប្បកិរិយាមិនឆេវឆាវក្នុងការដោះស្រាយបញ្ហាជាមួយអ្នកដទៃ* ។

នៅក្នុងជំពូក ៤ ចែងបញ្ជាក់ឡើងវិញពីគំរូនៃការរឹងប៉ឹងចំពោះសេចក្ដីពិត ហើយសុភាពទន់ភ្លន់ជាមួយមនុស្សទូទៅ ។ តាមទស្សនៈនៃ អំពើឃោរឃៅនៃថ្ងៃចុងក្រោយ និង ការធ្វើទុក្ខបុកម្នេញដែលរង់ចាំពួកអ្នកដែលកោតខ្លាចព្រះ [២៧] ក៏ចូលចិត្តនិយាយទន់ភ្លន់ចំពោះសេចក្ដីបង្រៀនត្រឹមត្រូវ [២៨] អ្នកដឹកនាំគ្រីស្ទបរិស័ទដែលត្រូវផ្សាយដំណឹងល្អដល់មនុស្សលោក ( គឺថាត្រូវរឹងប៉ឹង

---

[២៦] *១ ថែស្សាឡូនីច ២:៧*

[២៧] *២ ធីម៉ូថេ ៣*

[២៨] *២ ធីម៉ូថេ ៤: ៣-៤*

សំរាប់សេចក្តីពិត )[២៩] ។ គាត់មិនត្រូវព្រមទទួលព្រមតាមវិញ្ញាណអាក្រក់ ឬ វិញ្ញាណនៃសម័យនេះឡើយ ។ ប៉ុន្តែយើងត្រូវសួរម្តងទៀតថាតើគាត់ត្រូវផ្សាយដំណឹងល្អទៅមនុស្សលោកដោយរបៀបណា? "ដោយអំណត់ និង បង្រៀនដោយប្រុងប្រយ័ត្ន" ។ ពាក្យអំណត់បានប្រែថា"ទ្រាំទ្រដោយអត់ធ្មត់ មិនខឹង ឬ មួម៉ៅ "។ គឺជា" ស្ថានភាពនៃអារម្មណ៍ស្ងប់សុខនៅចំពោះមុខនៃការ អុចអាលបណ្តាលឲ្យខឹង ឬ ការធ្លោយការណ៍អ្វីមួយ និងដោយគ្មានការរអ៊ូរទាំ ឬ ខឹងអ្វីឡើយ"[៣០]។ ធីម៉ូថេ និង យើងដែលដើរតាមសេចក្តីបង្រៀនរបស់ លោក ប៉ូល មិនត្រូវឆាប់ខឹងជាមួយអ្នកដែលប្រឆាំង ជាមួយនឹងយើងឡើយ ប៉ុន្តែត្រូវទ្រាំទ្រចំពោះការរិះគន់ ឬ ចំអកឡកឡឺយពីអ្នកដទៃដោយមិនស្រែក ជំទាលស្តីបន្ទោស ឬ ពឹងផ្អែកពាក្យខឹងឯង តែត្រូវឆ្លើយតបទៅគេវិញដោយមាន សេចក្តីបង្រៀនដោយប្រុងប្រយ័ត្ន ។ ការប្តេជ្ញាចំពោះសេចក្តីពិតយ៉ាងម៉ឺងម៉ាត់ មិនតម្រូវឲ្យយើងតបតជាមួយអ្នកដែលប្រឆាំងនឹងយើងតាមបែបមិនត្រឹមត្រូវ នោះឡើយ។ រឹងប៉ឹងចំពោះសេចក្តីពិត ... តែសុភាពទន់ភ្លន់ជាមនុស្សទូទៅ ។

*១ ពេត្រុស ៣:១៥-១៦*។ ពេត្រុសមានប្រសាសន៍ដូចគ្នានេះដែរ ។ ពេត្រុសចាប់ផ្តើមខគម្ពីរទាំងនេះដោយនិយាយថាអ្នកអានរបស់គាត់ត្រូវ៖ ទី ១). ត្រូវទុកព្រះគ្រីស្តជាព្រះអម្ចាស់នៅក្នុងដួងចិត្ត ហើយនិងទី ២). ត្រូវ ត្រៀមជានិច្ច ដើម្បីពន្យល់ និង ការពារសេចក្តីសង្ឃឹមរបស់ខ្លួន ។ ការនេះឯង ដែលមានន័យថា រឹងប៉ឹងសំរាប់សេចក្តីពិត គឺរឹងប៉ឹងនៅក្នុងគំនិត ដើម្បីឲ្យ អាចពន្យល់ប្រាប់ពីហេតុផលដល់គេ និង រឹងប៉ឹងនៅក្នុងឆន្ទៈដើម្បីឲ្យអាច ជ្រើសរើសយកព្រះគ្រីស្តជាព្រះអម្ចាស់នៅក្នុងជីវិតរបស់ខ្លួន ។

---

[២៩] *២ ធីម៉ូថេ ៤: ២*

[៣០] Johannes P. Louw and Eugene A. Nida, eds., *Greek-English Lexicon of the New Testament based on Semantic Domains* in *Bible Windows 6.0* (Cedar Hill, Texas: Silver Mountain Software, 2001), s.v. μακροθυμια, ας *f* patience 25.167.

" សុភាពទន់ភ្លន់ជាមួយមនុស្សទូទៅ " ដោយដើរតាមសេចក្តីបង្រៀនរបស់ពួកសាវ័កដែលទាក់ទងទៅនឹងរបៀបរឹងប៉ឹងនេះ ដែលហ៊ានវែកញែករកហេតុផលដើម្បីការពារជំនឿរបស់ខ្លួនគឺ " ដោយសុភាពទន់ភ្លន់ និងដោយគោរពរាប់អាន ..." ។ ចំពោះការ " សុភាពទន់ភ្លន់" លោកពេត្រុសបានលើកឡើងនូវពាក្យសំដីដដែលដូចដែល លោកប៉ូលបានប្រើនៅក្នុង ១ ថែស្សាឡូនិច ២ [៣១]។ ពាក្យ " គោរពរាប់អាន" គឺជាពាក្យដែលគេតែងតែបកប្រែ "គោរពកោតខ្លាច" ។ ពាក្យនោះជួនកាលមានន័យថាភ័យខ្លាចដែលធ្វើឲ្យមនុស្សនោះភ័យរត់គេច ។ ពាក្យនេះក៏គេប្រើដើម្បីពណ៌នាពីការគោរពកោតខ្លាចដល់ព្រះដែរ ។ ដោយព្រោះតែព្រះនោះឯង ទើបមនុស្សបង្ហាញពីការ ខ្លាចស្ញប់ស្ញែង និងគោរពកោតខ្លាច ។ អាកប្បកិរិយាបែបនោះឯងដែលត្រូវប្រកាន់ខ្ជាប់ពេលយើងប្រព្រឹត្តជាមួយមនុស្សដទៃ សូម្បីតែជាមួយមនុស្សដែលបានសួរដេញដោលពីជំនឿគ្រីស្តបរិស័ទរបស់យើងក៏ដោយ ។ យើងមិនត្រូវនិយាយលេងសើចបែបចំអកឡកឡឺយនិយាយបញ្ឈឺនិយាយឌឺ ឬ សម្តែងអាការៈមិនចាប់អារម្មណ៍ចំពោះគេឡើយ ។ លោកប៉ូលបានណែនាំដូចគ្នានេះដែរនៅពេលដែលគាត់បង្រៀនថាយើងត្រូវ " បង្ហាញពីការបន្ទាបខ្លួនពិតដល់មនុស្សទាំងអស់ " [៣២] ហើយលោកយ៉ាកុប នៅពេលដែលគាត់ព្រមានចំពោះការដាក់បណ្តាសាដល់មនុស្ស [៣៣] ។

---

*[៣១] ពាក្យនោះគេបានប្រើ១១ ដងនៅក្នុងគម្ពីរសញ្ញាថ្មី ១កូរិនថូស ៤:២១; ២កូរិនថូស ១០:១; កាឡាទី ៥:២៣ ; ៦:១; អេភេសូរ ៤:២ កូឡុស ៣:១២; ២ធីម៉ូថេ ២:២៥; ទីតុស ៣:២; យ៉ាកុប ១:២១; ៣:១៣; ១ពេត្រុស៣:១៦ សូមអានក្នុងម៉ាថាយ ៥:៥; ១១:២៩; ២១:៥ និងក្នុង ១ធីម៉ូថេ ៦:១១ ។*

*[៣២] ទីតុស ៣:២*

*[៣៣] យ៉ាកុប ៣:៩-១២*

ហេតុផលនៃការដោះស្រាយបញ្ហាដោយសុភាព

តែហេតុអ្វីចាំបាច់សុភាព ? ហេតុអ្វីបានជាយើងមិនរឹងប៉ឹងនៅក្នុងការដោះស្រាយរបស់យើងជាមួយមនុស្សទាំងពួងគឺ ត្រូវរឹងប៉ឹងដូចដែលយើងត្រូវរឹងប៉ឹងចំពោះសេចក្តីពិតនោះ ? ព្រះគម្ពីរបានផ្តល់នូវការណែនាំមួយចំនួនគឺ ៖

*យើងក៏មានចំណុចខ្សោយដែរ ។* នៅក្នុងការពណ៌នាពីការថ្វាយបង្គំនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពួកសាសន៍ហេព្រើរបាននិយាយថា ពួកមហាបូជាចារ្យ" អាចដោះស្រាយបញ្ហាយ៉ាងសុភាពជាមួយអស់អ្នកណាដែលអវិជ្ជា និង អ្នកដែលនឹងវង្វេងចេញពីជំនឿដោយហេតុថាខ្លួនគាត់ផ្ទាល់ គឺមានសេចក្តីកំសោយដែរ" [៣៤] ការរំលឹកនឹកចាំពីអំពើបាបរបស់យើងផ្ទាល់គឺជាឱសថដ៏ពូកែដែលអាចជួយកែយើងពីជំងឺនៃការមានអំនួត។ លោកសាវកប៉ូលមានប្រសាសន៍ដូចគ្នានេះដែរ នៅពេលដែលគាត់រំលឹកដល់ លោកទីតុសដែលថា "នៅពេលមួយយើងក៏ល្ងីល្ងើមិនស្តាប់បង្គាប់បោកបញ្ឆោត និងជាប់ជាបាវបំរើដល់តណ្ហាគ្រប់យ៉ាង និងការភ្លើតភ្លើនគ្រប់ជំពូកដូចគេដែរ ។ យើងរស់ក្នុងជីវិតដែលច្រណែនឈ្នានីស និង ចងអាឃាត ព្យាបាត សំអប់ និង ស្អប់គ្នាទៅវិញទៅមក " [៣៥] ។ ភាពកំសោយនៅពេលបច្ចុប្បន្ន និង ភាពល្ងង់ល្ងើពីអតីតកាលបណ្តាលឲ្យយើងចេះបន្ទាបខ្លួន និង ចេះប្រព្រឹត្តដោយសុភាពចំពោះអស់អ្នកដែលកំពុងវង្វេងបែកចេញពីសេចក្តីពិត ។

*អ្នកដទៃប្រហែលជាអាចនិយាយត្រូវ* ។ គ្រីស្តបរិស័ទខ្លះជឿថា មានតែគេទេដែលមានសេចក្តីពិត និង ជាសេចក្តីពិតតែមួយប៉ុណ្ណោះចំណែកឯអ្វីៗគ្រប់យ៉ាងដែលអ្នកដទៃទៀតជឿគឺសុទ្ធតែខុសឆ្គងទាំងអស់។ គឺមិនពិតតែទាំងពីរ ។

អ័ប្រាហាំជាមនុស្សដែលមានកិត្តិយសជាងគេបំផុតនៅក្នុងព្រះគម្ពីរសញ្ញាចាស់តាមដែលយើងបានអានមក ។ គាត់ជាស្ថាបនិកនៃជនជាតិ

---

[៣៤] *ហេព្រើរ ៥: ២*

[៣៥] *ទីតុស ៣:៣*

យូដា និងជា "បិតានៃជំនឿរបស់មនុស្សទាំងអស់ "[៣៦]។ ជំនឿរបស់គាត់បានលើកស្ទួយគាត់ទៅជាមិត្តសម្លាញ់ជិតស្និទ្ធជាមួយព្រះជាម្ចាស់ [៣៧]។ តែទោះជាយ៉ាងនោះក៏ដោយគាត់ក៏មិនមែនត្រូវរហូតនោះដែរ ។

មានពេលម្តងនោះ អ័ប្រាហាំ បានទៅតាំងទីលំនៅត្រង់កេរ៉ា ។ នៅទីនោះហើយដែលគាត់បានកុហកថា សារ៉ាជាប្អូនរបស់គាត់ និងសារ៉ា ធ្លាក់ខ្លួនទៅរស់នៅក្នុងកន្លែងសរិតសំរាំងស្ត្រីសំរាប់ទុកឲ្យស្តេចអ័ប៊ីម៉្មាឡិចទៅវិញ ។ ដើម្បីកែខៃបញ្ហានេះឡើងវិញ ព្រះជាម្ចាស់មិនបានមាន បន្ទូលមកអ័ប្រាហាំទេ ដែលមនុស្សទាំងគិតថាព្រះជាម្ចាស់គួរតែមានបន្ទូលមកអ័ប្រាហាំ តែព្រះអង្គបែរជាមានបន្ទូលទៅកាន់ស្តេចសាសន៍ ភីលីស្ទីនទៅវិញ ! [៣៨] ។ ដោយសារតែការខ្វះជំនឿ និងការទុកចិត្តលើគ្រោងការណ៍ដែលមិនត្រឹមត្រូវរបស់គាត់នោះ អ័ប្រាហាំបានធ្វើឲ្យខ្លួនគាត់បាត់ឱកាសនៃការឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ដើម្បីដោះស្រាយបញ្ហាចំពោះមុខ ។ ព្រះជាម្ចាស់មានបន្ទូលទៅព្រមានដល់ស្តេច អ័ប៊ីម៉្មាឡិច ដែលអាចស្តារស្ថានការណ៍ដល់នាងសារ៉ាបាន និង នៅពេលជាមួយគ្នានោះដែរ ព្រះជាម្ចាស់បានប្រើឲ្យស្តេចបន្ទោសដល់អ័ប្រាហាំដែរ ។ អ័ប្រាហាំជាអ្នកជឿ អ្នកចុះសន្និសញ្ញាជាមួយព្រះជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ និង ជាបិតានៃជំនឿរបស់មនុស្សដែលបានជឿព្រះទាំងអស់បានស្តាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់នៅពេលនេះចេញពីមាត់នៃសាសន៍ដទៃ គឺជាស្តេចនៃសាសន៍ភីលីស្ទីនទៅវិញ ។ គាត់បានកុហកដោយគាត់បានគិតស្មានថានៅកន្លែងនោះប្រហែលជាគ្មាន " ការកោតខ្លាច

---

[៣៦] *រ៉ូម ៤:១១- ១២; ១៦-១៧*

[៣៧] *យ៉ាកុប ២:២៣*

[៣៨] *លោកុប្បត្តិ ២០:១; ២១:២២; ៣៤* . Cp. Isaac's experience with another Abimelech in Gen 26:1.

ព្រះទេមើលទៅ"[៣៩] ដូចដែលស្ត្រីស្តបរិស័ទខ្លះសម័យសព្វថ្ងៃបានគិតដូច្នោះដែរ ព្រោះគាត់គិតថាអ្នកដែលគាត់កំពុងរស់នៅជាមួយនោះសុទ្ធតែអ្នកមិនជឿ ។

ការណ៍បែបនេះមិនមែនគ្រាន់តែមានម្តងនៅក្នុងព្រះគម្ពីរប៉ុណ្ណោះទេ ។ យ៉ូសៀសជាស្តេចដែលកោតខ្លាចព្រះសោយរាជ្យនៅក្នុងអាណាចក្រយូដា ដែល"បានប្រព្រឹត្តត្រឹមត្រូវនៅព្រះនេត្រព្រះយេហូវ៉ាព្រមទាំងដើរតាមអស់ទាំងផ្លូវរបស់ដាវីឌជាព្ធយុកោទ្រង់ផងឥតងាកបែរទៅខាងស្តាំឬឆ្វេងឡើយ"[៤០]។ ព្រះគម្ពីរបានចែងថា"គ្មានស្តេចណានៅខាងមុខ និង នៅខាងក្រោយស្តេចយ៉ូសៀសមានចិត្តដូចជាស្តេចអង្គនេះដែលបានបែរមករកព្រះយេហូវ៉ាឲ្យអស់ពីចិត្តអស់ពីព្រលឹង ហើយអស់ពីកម្លាំងតាមគ្រប់ទាំងក្រឹត្យវិន័យរបស់លោកម៉ូសេឡើយ"[៤១] ។

តែផ្ទុយទៅវិញ ស្តេចផារ៉ោននៃប្រទេសអេហ្សីប ជាទូទៅមិនបានបង្ហាញថា បាននៅកៀកកិតជាមួយព្រះជាម្ចាស់ឡើយ ។ តែនៅពេលដែលស្តេចអេហ្សីបព្រះនាមនេកោបានលើកទ័ពទៅច្បាំងជាមួយពួកបាប៊ីឡូនទ្រង់បានព្រមានដល់ស្តេចយូសៀសមិនឲ្យប្រឆាំងនឹងទ្រង់ដោយបន្ទូលថា៖" ព្រះក៏បានបង្គាប់ឲ្យយើងប្រញាប់នឹងធ្វើដែរ ដូច្នោះកុំឲ្យឃាត់ឃាំងព្រះដែលគង់ជាមួយនឹងយើងឡើយ ក្រែងព្រះបំផ្លាញទ្រង់ទៅ" គួរឲ្យសោកស្តាយព្រះគម្ពីរបានចែងថាស្តេចយ៉ូសៀសមិនព្រមថយបែរចេញពីនេកោទេឥតស្តាប់តាមពាក្យរបស់នេកោដែលមកពីព្រះឱស្ឋនៃព្រះឡើយ ។ ហើយយាងទៅច្បាំងនៅត្រង់ច្រកភ្នំ មេគីដោ ពួកពលធ្នូក៏បាញ់ត្រូវស្តេច យ៉ូសៀស ហើយទ្រង់ក៏

---

*[៣៩] លោកុប្បត្តិ ២០:២១*

*[៤០] របាក្សត្រ ៣៤:១*

*[៤១] ២ ពង្សាវតារក្សត្រ ២៣:២៥*

សុគតទៅ [៤២]។ ស្តេចដែលកោតខ្លាចព្រះបែរជាមិនព្រមស្តាប់តាមព្រះសូរសៀង របស់ព្រះជាម្ចាស់ដែលកើតចេញពីប្រភពមួយដែលរកនឹកស្មានមិនដល់ ។

ព្រះយេស៊ូបានសង្កេតឃើញថា "មនុស្សនៃលោកិយនេះមាន ប្រាជ្ញា ក្នុងការដោះស្រាយបញ្ហាជាមួយមនុស្សជំនាន់នេះ ជាងមនុស្សខាងពន្លឺ" [៤៣]។ សុភាសិតបានចែងថា យើងគួររៀនយកគំរូតាមសត្វស្រមោច[៤៤] ។ សូម្បីតែ សត្វលា និង ដុំថ្មពេលខ្លះក៏មានរឿងត្រូវនិយាយដែរ [៤៥] ។ មិនថាឡើយយើង មានជំនឿ និង បានដើរកៀកកិតនឹងព្រះអង្គជិតជាងអ័ប្រាហាំ និងមានចិត្ត ឆេះឆួល ស្វែងរកព្រះយេហូវ៉ាច្រើនជាងស្តេច យ៉ូសៀស ប៉ុណ្ណានោះទេ យើងក៏ អាចធ្វើមិនអើពើចំពោះអ្នកដែលមិនមែនជាអ្នកជឿដូចយើងដូច្នេះដែរ ។

*ការប្រើសំដីគ្រោតគ្រោះបោះបោកនោះគឺជាឧបករណ៍ដែលពួកខុសឆ្គងគេ ប្រើ ។* ថ្វីដ្បិតតែមនុស្សមួយចំនួនគិតថា ការនិយាយពុៗ និង និយាយបង្រ្គប គេនោះ គឺប្រាកដជាគាត់មានសេចក្តីពិតមកចែកចាយច្បាស់ជាង តាមពិត ទៅការនិយាយពុៗ និង សេចក្តីពិតនោះវាមិនទាក់ទងគ្នាឡើយ ។ ការនិយាយ មួលបង្កាច់ និង ប្រើសំដីបង្រ្គបនោះគឺជាឧបករណ៍ដែលពួកគ្រូ ក្លែងក្លាយគេប្រើ គឺគេប្រើដើម្បីគ្របបាំងនូវចំណុចខ្សោយរបស់គេ និង ដើម្បីទាក់ទាញមនុស្ស ស៊ើកៗឲ្យទៅតាមគេទៅវិញទេ ។ មានតែ "មនុស្សគ្មានព្រះ និង "អ្នកដែល ស្រមើលស្រមៃ " ដែលប្រើពាក្យ "មួលបង្កាច់ "សូម្បីតែពួកទេវតាក៏មិន លើកលែង ផងនិង " និយាយបង្រ្គបប្រឆាំងនូវអ្វីដែលគេមិនយល់ " ។ គេខ្លាំងជាងមហាទេវតាមីកែលទៅទៀតដែលមិនហ៊ាននិយាយទាស់ប្រឆាំង សូម្បីតែដឹងច្បាស់ថា សាតាំងជាខ្មាំងសត្រូវក៏ដោយ[៤៦] ។

[៤២] ២របាក្សត្រ ៣៥:២០-២៤

[៤៣] លូកា ១៦:៨

[៤៤] សុភាសិត ៦:៦ -១១

[៤៥] ជនគណនា ២២:២៨-៣១; លូកា ១៩:៤០

[៤៦] យូដាស ៨:១០ ជិតតែស៊ីគ្នាទីង ២ ពេត្រុស ២:១០-១២

*ការប្រើពាក្យសុភាពគឺចេញពីមនុស្សដែលគោរពខ្លាចព្រះគឺជាគំរូដ៏ឆ្លាតវៃ ។* ផ្ទុយទៅវិញគ្រូដែលមានប្រាជ្ញាចេះទប់អណ្តាតរបស់ខ្លួនគឺមិនប្រើដើម្បីដាក់ " បណ្តាសាដល់មនុស្សដែលជាស្នាព្រះហស្តរបស់ព្រះឡើយ "។ គាត់បានបង្ហាញពីភាពវៃឆ្លាតរបស់គាត់ " ដោយការរស់នៅក្នុងជីវិតល្អប្រពៃដោយការប្រព្រឹត្តិដែលបន្ទាបខ្លួនគឺផុសចេញពីគតិបណ្ឌិត "។ ប្រាជ្ញាមកពីស្ថានលើគឺមិនច្រណែន ឬ មិនលោភលន់តែបរិសុទ្ធមានមេត្រីភាព និងចេះយោគយល់ [៨៧] ។

*ព្រះយេស៊ូដោះស្រាយបញ្ហាដោយសុភាព ។* នេះជារបៀបមួយព្រះយេស៊ូបានបំរើការងារព័ន្ធកិច្ច ។ នៅក្នុងការស្វែងរកពីរបៀបបង្ហាញប្រាប់ពីរូបភាពនៃព័ន្ធកិច្ចរបស់ព្រះយេស៊ូលោកម៉ាថាយបានដកស្រង់សំដីរបស់ហោរាអេសាយ ៖

> " មើលអ្នកបំរើដែលអញបានរើសតាំង ជាអ្នកស្ងួនភ្ងាដែលជាទីពេញចិត្តអញ អញនឹងដាក់វិញ្ញាណអញឲ្យសណ្ឋិតនៅលើទ្រង់ហើយ ទ្រង់នឹងថ្លែងប្រាប់ពីសេចក្តីយុត្តិធម៌ដល់សាសន៍ដទៃទ្រង់នឹងមិនតតាំងនឹងគេ ឬ ស្រែកសំរែកឡើយ នឹងគ្មានអ្នកណាឮសម្លេងទ្រង់នៅក្នុងផ្លូវទេទ្រង់នឹងមិនផ្តាច់ដើមត្រែងដែលបាក់ក៏មិនលត់ប្រឆេះដែលនៅហុយឡើយ ទាល់តែបាននាំសេចក្តីយុត្តិធម៌ឲ្យមានជ័យជំនះហើយអស់ទាំងសាសន៍ដទៃនឹងមានសេចក្តីសង្ឃឹមដោយនូវឈ្មោះទ្រង់ " [៨៨] ។

នៅក្នុងខ ១៩ មិនមានន័យថាព្រះយេស៊ូបានមានបន្ទូលសោះឡើយនោះទេ ដ្បិតនៅ ខ ខាងដើមបានចែងពីព្រះអង្គមានបន្ទូលប្រកាសពីសេចក្តី

---

[៨៧] *យ៉ាកុប ៣:៩-១៨*

[៨៨] *ម៉ាថាយ ១២:១៨-២១; អេសាយ ៤២:១-៤*

យុត្តិធម៌ ។ តែផ្ទុយទៅវិញត្រង់នេះចង់បញ្ជាក់ពី " ភាពសុភាពទន់ភ្លន់ និង ការបន្ទាបខ្លួន ( ១១:២៩ ) ភាពស្ងប់ស្ងាត់នៃការដកថយចេញទៅ ... និងការ បង្ហាញពីភាពជាព្រះមេស្ស៊ីរបស់ព្រះអង្គដែលមិនក្រអឺតក្រទម ឬ អួតអាង នោះឡើយ"[៤៩] ។ នៅពេលដែលពេត្រុសចង់សង្ខេបពីព័ន្ធកិច្ចរបស់ព្រះយេស៊ូ គាត់បាននិយាយពី " របៀបដែលព្រះជាម្ចាស់បានចាក់ ប្រេងតាំងព្រះយេស៊ូ ជាអ្នកស្រុកណាសារ៉ែតដោយព្រះវិញ្ញាណបរិសុទ្ធនិងអំណាចចេស្ដា និង របៀប ដែលព្រះអង្គចេញទៅគ្រប់ទិសទីដើម្បីធ្វើការល្អ និង ការប្រោសជម្ងឺ..."[៥០]។ គំរូដែលជាធម្មតាដែលព្រះយេស៊ូបានធ្វើដែលយើងគួរយកតម្រាប់តាមនោះ គឺព្រះអង្គមិនប្រឈមមុខដោយនិយាយសង្គ្រប់ឡើយ ។

## នៅពេលដែលត្រូវបំបែកគំរូដ៏សុភាពនោះហើយ

ទោះបីជាយ៉ាងណាក៏ដោយមានពេលខ្លះនោះព្រះយេស៊ូបានមាន បន្ទូលខ្លាំងមែនទែន ។ នៅគម្ពីរម៉ាថាយ ២៣ ព្រះអង្គបានមានបន្ទូលទាស់ទទឹង នឹង ពួកបណ្ឌិតក្រឹត្យវិន័យ និង ពួកផារាស៊ីដោយប្រើពាក្យរវរហើយប្រាំពីរដង ព្រោះពួកនោះព្រះអង្គបានចាត់ទុកជាមនុស្សមានពុត កូនប្រុសនៃស្ថាននរក អ្នកខ្វាក់ដឹកដៃអ្នកភ្លើ ផ្នូរខ្មោចដែលលាបពណ៌សពីខាងក្រៅ ពួកពស់ និង ពួកហ្វូង ពស់វែក ។ ការណ៍នេះប្រាកដជាមិនមែនជាពាក្យទន់ភ្លន់ឡើយ ។ ក្រៅពីព្រះយេស៊ូ គេអាចនឹកគិតដល់លោកអេលីយ៉ា ពេលដែលគាត់ប្រឈម មុខជាមួយពួកហោរានៃព្រះបាល[៥១] លោកប៉ូល ជាមួយនឹងអេលីម៉ាស[៥២] និង

[៤៩] D. A. Carson, "Matthew," in *The Expositor's Bible Commentary*, gen. ed. Frank E. Gæbelein, CD ROM ed. (Grand Rapids: Zondervan, n.d.), on Matt 12:15–21.

[៥០] *កិច្ចការ ១០:៣៨*

[៥១] *១ ពង្សាវក្សត្រ ១៨:២៧*

[៥២] *កិច្ចការ ១៣:៩-១១*

លោកអេសាយ ជាមួយនិងពួកថ្វាយបង្គំព្រះ [៩៣] ។ ហេតុអ្វីបានជានៅក្នុងឱកាសនេះ អ្នកបំរើការងារព្រះជាម្ចាស់បែរចេញពីគំរូនៃការសុភាពទន់ភ្លន់ជាធម្មតាទៅវិញ ?

គន្លឹះសំខាន់ទីមួយគឺដោយសារតែពួកមនុស្សទទួលរងនូវការស្តីបន្ទោសខ្លាំងៗបែបនេះ គឺពួកគេជាមនុស្សដែលគួរយល់ដឹងពីសេចក្តីពិតប្រសើរជាងគេ ។ ពួកបណ្ឌិតខាងក្រឹត្យវិន័យ និងពួកផារាស៊ីបានសិក្សាពីក្រឹត្យវិន័យរបស់ព្រះជាម្ចាស់យូរយារណាស់មកហើយ សេចក្តីកោតខ្លាចព្រះនោះគេមានពេលល្មមគ្រប់គ្រាន់ហើយ តែគេមានបំណងមើលរំលងពីក្រឹត្យវិន័យទាំងនោះទៅវិញ ។ អេលីម៉ាសជាសាសន៍យូដាដែលជាអ្នកមានឱកាសស្គាល់សេចក្តីពិតច្បាស់ តែបែរជាទៅថ្លែងទំនាយក្លែងក្លាយ និង រកស៊ីជាគ្រូទាយទៅវិញ ។ ការប្រព្រឹត្តិរបស់លោកប៉ូលចំពោះគាត់គឺខុសប្លែកស្រឡះពីការដែល លោកប៉ូលបានធ្វើនៅក្នុងកិច្ចការ ១៤:១១-១៨ គឺគាត់បាននិយាយទទូចអង្វរជាមួយសាសន៍ដទៃ ដោយគ្មានប្រើពាក្យស្តីបន្ទោសឡើយ ។ ពួកអ៊ីស្រាអែលដែលលោកអីលីយ៉ាបានប្រឈមមុខតទល់ជាមួយនោះគឺ ពួកគេគួរតែយល់ដឹងពីព្រះយេហូវ៉ា បានច្បាស់រួចហើយ ។ ពួកអ្នកថ្វាយបង្គំរូបព្រះដែលលោកអេសាយ និយាយចំអកឲ្យនោះគឺជាពួកអ្នកមិនយល់ពីរឿងរ៉ាវដ៏សាមញ្ញបំផុតនោះឯង [៩៤] ។ កំហុសរបស់គេសមតែនឹងស្តីបន្ទោសឲ្យយ៉ាងខ្លាំង គឺមិនសមប្រើពាក្យស្លូតបូតឡើយ ។

ទីពីរចំពោះអ្នកទាំងនោះដែលត្រូវបានលោកអេសាយបន្ទោសនោះមិនគ្រាន់តែល្ងីល្ងើតែខ្លួនឯងនោះឡើយ ថែមទាំងនាំអ្នកដទៃឲ្យវង្វេងទៅតាមខ្លួនទៀតផង ។ ពួកបណ្ឌិតខាងក្រឹត្យវិន័យ និង ពួកផារាស៊ីមិនគ្រាន់តែជាមនុស្សខ្វាក់វង្វេងប៉ុណ្ណោះទេ តែជាអ្នកដឹកនាំដែលខ្វាក់វង្វេងទៀតផង ។

---

[៩៣] *អេសាយ ៤៤:៩-២០*

[៩៤] *អេសាយ ៤៤:១៩ -២០*

អេលីម៉ាសបានបង្វែរលោក សើរកាល- ប៉ូឡូស មិនជឿសេចក្តីពិត។ លោកប៉ូល បានប្រឆាំងជាមួយ ពេត្រុសដោយផ្ទាល់នៅ ចំពោះមុខមនុស្សដទៃ (ដោយមិនក្រែងចិត្តថា ពេត្រុសបាក់មុខឡើយ) ពីព្រោះ"សាសន៍យូដាដទៃទៀតបានចូលរួមក្នុងពិធីកំពុតរបស់គាត់"និង"សូម្បីតែបាណាបាសក៏ត្រូវគេនាំឲ្យគាត់វង្វេងដែរ"[៥៥]។ ក្រោយមកគាត់បានឲ្យទីតុសស្តីបន្ទោសយ៉ាងខ្លាំងទាស់នឹងពួកបណ្ឌិតផ្នែកច្បាប់" ពីព្រោះពួកគេបានផ្តួលពួកអ្នកផ្ទះទាំងមូល[៥៦] ។

យើងអាចសរុបសេចក្តីបានចំពោះគំរូជាទូទៅនៃការបំរើព័ន្ធកិច្ចគឺតាមពិតទៅការចាប់ផ្តើមដំបូងនោះ គឺយើងត្រូវប្រើរបៀបទន់ភ្លន់ ។ នេះគឺជាអ្វីដែលអត្ថបទគម្ពីរត្រង់នេះបានបង្រៀនយើង និងជាគំរូជាច្រើន ហើយនិងសាច់រឿងដែលបានគូសបញ្ជាក់បង្ហាញមកនោះ ។ ទោះជាយ៉ាងណាក៏ដោយមានឱកាសជាច្រើន នៅពេលដែលមនុស្សយើងខ្វះការទទួលខុសត្រូវ និងបែរទៅទទួលយកនូវការខុសឆ្គងយ៉ាងសកម្មនោះ គឺគេត្រូវតែទទួលរងការប្រឆាំងតទល់យ៉ាងខ្លាំង ព្រោះតែគេបានទទួលនូវគោលលិទ្ធិដែលខុសឆ្គងមកនាំអ្នកដទៃឲ្យវង្វេង ។

## មានយន្តការបីយ៉ាងនៃការសុភាពទន់ភ្លន់

## ញែកបុគ្គលនោះឲ្យដាច់ចេញបញ្ហា

ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការដែលគួរឲ្យយើងយកមកប្រើ និង ដំណើរការមួយដែលយើងគួរយកមកធ្វើតាមមុនគេនោះ គឺ គូសបន្ទាត់ឲ្យដាច់ពីការបង្រៀនក្លែងក្លាយ និងមនុស្សដែលបានកាន់តាមសេចក្តីបង្រៀននោះ ។ សេចក្តីបង្រៀនក្លែងក្លាយនោះ គឺជាបញ្ហាមិនមែនជាមនុស្សទេ ដែលជាបញ្ហាយើងត្រូវដោះស្រាយ ។

---

*[៥៥] កាឡាទី ២:១១-១៣ អត្ថបទនេះមិនរាប់បញ្ចូលពាក្យស្តីបន្ទោសនៅក្នុងគំរូលើកមុនៗផង តែគឺជាការណែនាំមួយបែបដែលច្ងទ់ច្ងរតទល់នឹងមហាសាវ័ក ។*

*[៥៦] ទីតុស ១:១០-១៣*

នៅក្នុងសៀវភៅរបស់ពួកលោក ហ្វីសស៊ើ យូរី និង ផាតថិន ស្ដីពីការចរចារបានលើកឡើងមកនិយាយនៅក្នុងជំពូកមួយ យ៉ាងច្បាស់ចំពោះការញែកមនុស្សចេញពីបញ្ហា [៥៧] ។ គេបានរំលឹកយើងយ៉ាងច្បាស់ថា ដំបូងពួកអ្នកចរចារគឺជាមនុស្ស ហើយនិងអ្នកចរចារគ្រប់រូបមានចំណាប់អារម្មណ៍ពីរបែប គឺទាក់ទងជាមួយសារធាតុនៃការចរចារ និងមួយទៀតទាក់ទងទំនាក់ទំនងនៃអ្នកចរចារ ។ នៅក្នុងជំពូកនៃសៀវភៅនោះបានបញ្ចប់សេចក្ដីដោយការសកបញ្ចូលពាក្យថា " ការញែកមនុស្សចេញពីបញ្ហាគឺមិនមែនជាការងារមួយលោកអ្នកអាចធ្វើតែម្ដងរួចហើយ បំភ្លេចចោលនោះឡើយ លោកអ្នកត្រូវកំណត់ក្នុងចិត្តជានិច្ចធ្វើការនោះរហូត ។ គោលការណ៍សំខាន់ជាមូលដ្ឋាន គឺត្រូវដោះស្រាយបញ្ហាជាមួយមនុស្សដោយយល់ពីតម្លៃគេជាមនុស្ស និង ដោះស្រាយជាមួយបញ្ហាគឺចាត់ទុកថាវាគ្រាន់តែជាបញ្ហាទុកឲ្យបញ្ហានោះវាស្ដែងចេញពីលទ្ធផលរបស់វាផ្ទាល់មក " [៥៨] ។

ម៉ាកហ្គ្រាត បានលើកយកឥរិយាបទនេះផ្ដោតសំខាន់លើការងារចរចារដែលមានលក្ខណៈខុសប្លែកគ្នា និងស្រង់យកគោលការណ៍នេះមកប្រើក្នុងការដោះស្រាយក្នុងកិច្ចការពារជំនឿរបស់គ្រីស្ទបរិស័ទ [៥៩]។ គាត់បានផ្ដល់នូវការណែនាំដូចខាងក្រោមនេះគឺ៖

ឧបមាថាលោកអ្នកកំពុងនិយាយជាមួយអ្នកដែលមួយជីវិតគាត់មិនជឿថាមានព្រះទេ គឺយើងនិយាយអំពីគំនិតរបស់គាត់ ។ ចំណុចសើៗ

---

[៥៧] Roger Fisher, William Ury, and Bruce Patton, *Getting to Yes: Negotiating Agreement Without Giving In*, 2nd ed., (Boston: Houghton Mifflin, 1991). Chapter two, "Separate the People from the Problem," occupies pages 17–39, and is the leading chapter in Part II, "The Method."

[៥៨] *ដូចលេខយោងទី ៥៧ ដែរ តែនៅទំព័រទី៣៩*

[៥៩] Alister E. McGrath, *Intellectuals Don't Need God & Other Modern Myths: Building Bridges to Faith through Apologetics* (Grand Rapids: Zondervan, 1993), 88–92.

ដែលយើងបានលើកមកនិយាយគឺថា តើព្រះមានមែន ឬ អត់ ។ ប៉ុន្តែបញ្ហាដែលស៊ីជម្រៅនោះ ប្រហែលជាអាចមានបញ្ហាជាច្រើនទៀត មាននៅក្នុងបុគ្គលនោះដែលយើងមិនបានដឹងច្បាស់ ។ គំនិតទាំងអស់អាចផុសឡើងនៅក្នុងគំនិតរបស់គាត់គឺថា ៖" ខ្ញុំជាមនុស្សដែលមិនថាមានព្រះអស់រយៈពេល ២៥ ឆ្នាំ ហើយគិតមកទល់ឥឡូវនេះ ។ នោះគឺជារយៈពេលយូរ ។ ម្យ៉ាងទៀតនោះអ្នកណាក៏គេដឹងថា ខ្ញុំជាមនុស្សដែលមិនជឿថាមានព្រះ ។ បើសិនជាខ្ញុំប្តូរគំនិតឥឡូវនេះ គេនឹងសើចចំអកឲ្យខ្ញុំជាមិនខាន ។ ខ្ញុំប្រាកដជាបាក់មុខ ។ កេរ្តិ៍ឈ្មោះរបស់ខ្ញុំផ្ទាល់គឺវាទាក់ទងផ្ទាល់នឹងគំនិតយល់ឃើញរបស់ខ្ញុំដែលមិនជឿថាមានព្រះនោះ ។ ខ្ញុំភ្ជាប់វាទៅនឹងស្ថានការណ៍នេះ ។ ជំនឿរបស់ខ្ញុំ និង អត្តសញ្ញាណរបស់ខ្ញុំអាច នឹង ច្របូកច្របល់គ្នាបន្តិច ។ បើសិនខ្ញុំប្តូរគំនិតរបស់ខ្ញុំចំពោះបញ្ហានេះខ្ញុំ ប្រហែលជាប់ក្នុងអារម្មណ៍ចោទប្រកាន់ពីស្ថានភាពអតីតកាលរបស់ខ្ញុំទាំងស្រុង" ។ អ្នកបញ្ចេញមតិការពារជំនឿរបស់ខ្លួនអាចងាយចាប់យកការប្រកាន់បែបនោះ តាមរបៀបដោះស្រាយបញ្ហាដែលខ្វះការប្រុងប្រយ័ត្ន និង ការប៉ិនប្រសព្វទៅនឹងរឿងដែលងាយប៉ះពាល់អារម្មណ៍របស់មនុស្ស [៦០]។

ដើម្បីកាត់បន្ថយនូវការសាងបញ្ហា កុំឲ្យធ្ងន់ធ្ងរឡើងនោះ ម៉ាកប្រ្កាត បានណែនាំថា ដំបូងត្រូវញែកមនុស្សចេញឲ្យដាច់ពីបញ្ហា និង បន្ទាប់មកគឺធ្វើឲ្យងាយស្រួលមនុស្សទាំងនោះប្តូរគំនិតរបស់គេ ។

បទគម្ពីរទំនងដូចជាគាំទ្រនូវគោលការណ៍បែបនោះ ។ សូមមើលត្រឡប់ទៅធីម៉ូថេ ២:២៤-២៦ យើងឃើញថាលោកប៉ូលបានលើកទឹកចិត្ត

---

[៦០] *ដូចលេខយោងទី ៥៩ ដែរ តែទៅទំព័រទី ៨៨*

ឲ្យប្រព្រឹត្តសុភាពដល់មនុស្សដែលជាប់នឹងសេចក្ដីបង្រៀនខុសឆ្គងដោយសង្ឃឹមថា បុគ្គលនោះនឹងលះបង់ចោលគំនិតខុសឆ្គងរបស់ខ្លួន ។ ខ្មាំងសត្រូវនៅក្នុងករណីនេះគឺអារក្សដែលវាប្រើល្បិចចាំចាប់អ្នកដែលប្រឆាំងនឹងគោលលិទ្ធិពិត ។ ការបង្រៀនដោយសុភាព និង ជំនួយអន្តរាគមន៍មកពីព្រះជាម្ចាស់ផងនោះ អាចនឹងជួយបើកភ្នែកខ្វាក់ឲ្យគេបានឃើញ និង ព្រមទទួលសេចក្ដីពិត ។ ២ កូរិនថូស ៤:១-៦បានចែងភាគច្រើនដូចគ្នានេះដែរ [៦១] ។

ការសុភាពទន់ភ្លន់នោះអាចទំនងជាឥរិយាបទល្អតែមួយគត់ គឺជាឥរិយាបទដែលពិបាកពណ៌នាក្នុងពាក្យណាមួយដែលចំត្រូវពិតប្រាកដ ។ ប៉ុន្តែមានដំណើរការដែលអាចប្រើដើម្បីធានាចំពោះគោលការណ៍សុភាពនោះថាល្អត្រឹមត្រូវ ។ ការញែកមនុស្សចេញពីបញ្ហានោះគឺជា ដំណើរការទីមួយ ។ ការស្ដាប់មុនពេលនិយាយនោះ និងការប្រើពាក្យស្រដៀងគ្នានោះ គឺជាដំណើរការពីរថែមទៀត ។ ការយកទាំងអស់នោះជាមួយគ្នាគឺគេបានលើកកំពស់ស្មារតីដែលអ្នកនិយាយមិនសូវស្ដាប់ចិត្តនូវអ្វីដែល គាត់ចង់និយាយប៉ុន្មាន គឺនិយាយឲ្យតែរួចៗទៅ គឺមានឥរិយាបទដែល "ទទួលយកគំនិតនោះ ឬ ទុកគំនិតនោះចោល" ។

---

*[៦១] នៅក្នុង ២ កូរិនថូស ៤ ប៉ូលបាននិយាយអំពីរបៀបដែលព្រះនៃសម័យនេះបានបិទភ្នែកទាំងគំនិតនៃអ្នកមិនជឿ ។ ហេតុដូច្នេះហើយគាត់ជាបញ្ហាដូចគ្នានឹងគោលលិទ្ធិដែលគាត់បង្រៀន ។ ការឆ្លើយតបចំពោះបញ្ហានេះដែលត្រឹមត្រូវនោះ គឺត្រូវលើកយកសេចក្ដីពិតឲ្យឃើញច្បាស់ហើយនឹងត្រូវចាប់ផ្ដើមយល់ពីមនសិការរបស់មនុស្ស ដោយការអធិប្បាយផ្សាយពីព្រះយេស៊ូជាព្រះអម្ចាស់និងទុកខ្លួនឯងជាអ្នកបំរើវិញ ។ ឃ្លាខាងលើទាំងពីរគឺស៊ីគ្នានឹងគំរូនៃការរឹងប៉ឹងចំពោះសេចក្ដីពិតតែសុភាពទន់ភ្លន់ជាមួយមនុស្ស ។*

## ស្តាប់មុននឹងនិយាយ

"អ្នកណាដែលឆ្លើយមុនដែលបានស្តាប់រឿងនោះរាប់ជាការចំកួត ហើយក៏ជាសេចក្តីខ្មាសដល់ខ្លួនផង" [៦២] មានគតិបណ្ឌិតក្នុងការស្តាប់ និង យល់ដឹងពីគ្នាមុននឹងមានបំណងនិយាយពីគតិលោក ឬ និយាយពីសាសនា ។ លោកប៉ូលបានហាត់ប្រើគោលការណ៍នេះ ដោយមិនគ្រាន់តែមើលសើៗនោះឡើយ តែគាត់ពិនិត្យមើលដោយយកចិត្តទុកដាក់លើកន្លែងថ្វាយបង្គំនៃអាសនារបស់ពួកអ្នកក្រុងអាថែន មុនគាត់លើកពីព្រះដែលគេពុំស្គាល់ [៦៣] ។ ឱកាសនេះឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្ររបស់គាត់នៃការយល់ដឹងនៃរឿងរ៉ាវទាំងអស់មនុស្សទាំងអស់ដើម្បីឲ្យអាចផ្សាយដំណឹងល្អដល់គេឲ្យបានច្រើនតាមដែលអាចធ្វើបាន ។ គោលបំណងរបស់គាត់មិនគ្រាន់តែនិយាយឲ្យតែបានច្រើន ហើយមិនខ្វល់ថាគេយល់ ឬ មិនយល់នោះទេ តែក្នុងគោលបំណងឲ្យគេបានជឿឲ្យបានច្រើនតាមដែលអាចធ្វើបាន [៦៤] ។

មានអ្វីដែលគេអាចហៅថា"បច្ចេកទេសនៃការស្តាប់ជាគំរូមាត្រដ្ឋាន"។ ទាំងនេះគឺ៖

យកចិត្តទុកដាក់យ៉ាងជិតដល់នូវអ្វីដែលគេបាននិយាយគឺ ត្រូវសុំឲ្យភាគីម្ខាងទៀតនិយាយចេញមកឲ្យបានច្បាស់ពិតប្រាកដនូវអ្វីដែលគេចង់និយាយ ហើយត្រូវសុំឲ្យគេលើកយកគំនិតនោះមកនិយាយម្តងទៀតបើសិននៅមានកន្លែងណាដែលមិនច្បាស់ ឬ នៅស្រពិចស្រពិល ។ ការងាររបស់អ្នកនៅពេលស្តាប់គេនិយាយមិនត្រូវស្តាប់រកឃ្លាណាមួយដែលត្រូវឆ្លើយទៅគេវិញឡើយ តែត្រូវខំស្តាប់ឲ្យយល់នូវអ្វីដែលគេចង់ និយាយឲ្យយើងយល់ដូចគេយល់ដោយខ្លួនគេផ្ទាល់ ។

---

[៦២] *សុភាសិត ១៨:១៣*

[៦៣] *កិច្ចការ ១៧: ២៣*

[៦៤] *១ កូរិនថូស ៩:១៩-២២*

ទទួលយកការយល់ឃើញសេចក្តីត្រូវការរបស់គេ និង កំរិតព្រំដែនរបស់គេ [៦៥] ។

ការងារសកម្មបែបនេះគឺការស្តាប់ដោយយកចិត្តទុកដាក់មិនមែនបានន័យថា យើងយល់ស្របតាមអ្វីដែលបាននិយាយប្រាប់មកយើងនោះឡើយ ។ ការយល់មិនមែនជាការព្រមទទួលស្របតាមនោះឡើយ ។ គេអាចយល់បានយ៉ាងល្អនៅពេលដែលភាគីម្ខាងទៀតបាននិយាយ ។ ប៉ុន្តែដរាបណាលោកអ្នកអាចបង្ហាញឲ្យគេឃើញថា លោកអ្នកបានយល់នូវអ្វីដែលគេយល់នោះ ទើបលោកអ្នកអាចពន្យល់នូវគំនិតយោបល់របស់លោកអ្នកដល់គេបាន ។ នៅពេលលោកអ្នកបានលើកយកពីករណីរបស់គេឲ្យបានយល់ បន្ទាប់មកវិលត្រឡប់វិញដោយលើកយកបញ្ហាទាំងឡាយដែលលោកអ្នករកឃើញនៅក្នុងសំណើរបស់គេ [៦៦] ។

តាមពិតទៅយើងអាចយល់ស្របជាមួយ នរណាម្នាក់បាន និង ទោះបីជាយ៉ាងណាក៏ដោយយើងអាចស្តាប់ និង ស្វែងយល់ពីគេបាន ។ ហេតុផល [ ការចូលទៅក្នុងគតិលោករបស់ម្នាក់ផ្សេងទៀត ] សំខាន់គឺថា យើងចង់បានហេតុការណ៍ពិត ។ អ្វីដែលអ៊ីត្លែរ៍ គិតនិងមានអារម្មណ៍នឹងបានធ្វើនោះ គឺជាហេតុការណ៍ពិត ។ ហេតុការណ៍ខាងពិតក្នុងអំពីអ៊ីត្លែរ៍ ជួយពន្យល់ឲ្យបានយល់ច្រើនពីស្រទាប់ខាងក្រៅនៃបញ្ហា ហើយយើងត្រូវការដឹងហេតុការណ៍ខាងក្នុងរបស់អ៊ីត្លែរ៍ឲ្យបានច្បាស់តាមដែលយើងអាចធ្វើបានបើសិនយើងមានបំណងចង់យល់ពីប្រវត្តិដ៏គួរឲ្យរន្ធត់កាលពីសម័យនោះ ។ ដូចគ្នាដែរបើសិនយើងមាន បំណងចង់រុករកឲ្យយល់ពីលក្ខណៈនិស្ស័យនៃលិទ្ធិព្រះពុទ្ធសាសនា យើង

---

៦៥ Fisher, Ury, and Patton, *Getting to Yes*, 34.

៦៦ *ដូចលេខយោងទី ៦៥ ដែរ តែនៅទំព័រទី ៣៥*

ត្រូវតែខំរកឲ្យយល់អត្ថន័យដែលពួកអ្នកកាន់សាសនាព្រះពុទ្ធគេបានកាន់ និង ស្វែងយល់តាមរយៈសៀវភៅសាសនានោះ ។ គំនិតរបស់យើងមិនមែនជាហេតុការណ៍ពួកគេឡើយ ប៉ុន្តែជាហេតុការណ៍ដែលស្តីពីជំនឿយើងទៅវិញទេ ។ ក្រោយមកពេលដែលយើងបានដឹងនូវអ្វីដែលពួកពុទ្ធសាសនាគេជឿនោះ គឺអាចជួយឲ្យយើង សំលៀងសំរួចជំនឿរបស់យើងផ្ទាល់ [៦៧] ។

## ផ្សាយដំណឹងល្អពីព្រះគ្រីស្ទដោយប្រើពាក្យស្រដៀងគ្នា

ចំពោះអ្នកទាំងឡាយណាដែលបានឲ្យតម្លៃតិចលើអ្នកស្តាប់របស់ខ្លួននោះ តែងតែផ្សាយសាររបស់ខ្លួននោះ តាមបែបស្រដៀងនឹង អ្វីដែលជារបស់ផងខ្លួនមិនថាពេលណាឡើយឲ្យតែគេចាប់ផ្តើមធ្វើការប្រាស្រ័យទាក់ទង ។ តើនរណានឹងខ្វល់ទៅនូវអ្វីដែលខ្ញុំនិយាយ ដោយទាក់ទាញចិត្តអាចយល់បាន ឬ ស៊ីនឹងស្ថានការណ៍របស់អ្នកស្តាប់របស់ខ្ញុំនោះ ? ខ្ញុំបានរៀបចំជាការអធិប្បាយយ៉ាងសំខាន់ ។ អ្វីដែលខ្ញុំនិយាយនោះគឺច្បាស់គ្រប់គ្រាន់សំរាប់ខ្ញុំហើយ ។ បើសិនជាគេចង់យល់គេត្រូវខំប្រឹងយល់ដោយខ្លួនឯងទៅ ។

ប្រហែលការណ៍នេះនិយាយហួសពីករណីនោះ ។ តែអ្នកដែលប្រាស្រ័យមានប្រសិទ្ធិភាពគឺអ្នកប្រាស្រ័យទាក់ទងដែលចេះប្រើពាក្យសុភាព គឺជាអ្នកដែលរៀនស្គាល់ពីអ្នកស្តាប់របស់ខ្លួន និង ប្រធានបទរបស់ខ្លួនឲ្យបានច្រើន ។ គាត់ជាអ្នកកាត់តម្រឹមឲ្យស៊ីនឹងស្ថានការណ៍ ។ ការសុភាពទន់ភ្លន់ជាមួយមនុស្ស រាប់បញ្ចូលទាំងការយល់ដឹង និង ខំធ្វើឲ្យការស្តាប់របស់គេបានកាន់តែងាយស្រួលឡើង ។

---

[៦៧] Ninian Smart, *Religion and the Western Mind* (Albany: State University of New York Press, 1987), 4.

នៅពេលថ្មីៗនេះ ខ្ញុំបានចូលរួមក្នុងការប្រជុំរបស់គ្រូគង្វាលនៅតាមជនបទនៃជនជាតិនៅភូមិភាគអាស៊ីដែលភាគច្រើនមិនសូវចេះអក្សរ អ្នកខ្លះមកពីនិន្នាការនយោបាយដ៏តឹងរឹង ។ មានមនុស្សជាច្រើនកំពុងស្រេកឃ្លាននូវការលើកទឹកចិត្ត ចង់បានការថ្វាយបង្គំ និង ចង់បានការបង្រៀននូវគោលជំនឿជាមូលដ្ឋាន ។ សិក្ខាសាលានេះបានរៀបចំឡើងដោយអង្គការផ្សាយដំណឹងល្អ ដែលមានស្ពុកស្ពម្ពមកពីបស្ចឹមប្រទេសហើយគេបានធ្វើការប្រជុំនៅកណ្ដាលទីក្រុង ។ ប្រាកដអត់សង្ស័យថា គោលបំណងរបស់អង្គការនោះ គឺប្រសើរខ្ពង់ខ្ពស់មែនទែន ។ ប៉ុន្តែនៅពេលដែលចាប់ផ្ដើមបើកកម្មវិធីគ្រូអធិប្បាយបាននិយាយអំពីសាខា របស់គាត់មាននៅប្រទេសនេះប្រទេសនោះអស់រយៈពេលយ៉ាងយូរ គឺគាត់បានធ្វើឲ្យអ្នកស្ដាប់មិនយល់អ្វីទាំងអស់ និងនៅតែស្រេកឃ្លានដដែល ។ តែផ្ទុយទៅវិញ បន្ទាប់ពីគាត់មានអ្នកប្រកាសដំណឹងម្នាក់ឡើងមកនិយាយប្រហែលបី ឬ បួននាទីថា៖" បងប្អូនអើយអ្នកខ្លះនៅក្នុងចំណោមបងប្អូនចេះប្រើបង្គន់ ហើយអ្នកខ្លះមិនទាន់ចេះប្រើទេ ។ ចំពោះអ្នកដែលចេះ សូមកុំសើចចំអកឲ្យអ្នកដែលមិនចេះតែត្រូវជួយណែនាំគ្នាទៅវិញទៅមក ។ នៅទីនេះគឺនៅក្នុងទីក្រុងមិនមែនជាការគួរសមឡើយក្នុងការស្ដោះទឹកមាត់លើជញ្ជាំង ឬ លើឥដ្ឋក្នុងសណ្ឋាគារ ។ ខ្ញុំដឹងថាបងប្អូនខ្លះធ្លាប់ខាកស្ដោះនៅឯភូមិស្រុករបស់បងប្អូន តែនៅទីនោះបើយើងខាកស្ដោះមិនមែនជាទីបន្ទាល់ល្អឡើយ ។ បើបងប្អូនចង់ ខាកស្ដោះ សូមចូលទៅក្នុងបន្ទប់ទឹក ឬចេញក្រៅ តែមិនត្រូវខាកស្ដោះដាក់ជញ្ជាំង ឬលើកំរាលសណ្ឋាគារឡើយ ។ អ្នកអធិប្បាយទីពីរនេះ គឺគាត់ស្គាល់មជ្ឈដ្ឋាន អ្នកស្ដាប់គាត់ច្បាស់ ។ ពាក្យសំដីរបស់គាត់ ទោះបីជាគាត់មិនបានរៀនជ្រៅជ្រះ និង ប្រើពាក្យល្អពិសេសដូចអ្នកទីមួយក៏ដោយ គឺគាត់បានសម្រេចដល់ទិសដៅគាត់បានច្រើនជាង ។

ព្រះជាម្ចាស់មិនគ្រាន់តែប្រាស្រ័យទាក់ទងដោយយកនិស្ស័យជាមនុស្សទេ តែព្រះអង្គធ្វើឲ្យការប្រាស្រ័យទាក់ទងរបស់ព្រះអង្គងាយយល់មិន

ស្មុគស្មាញទៀតផង ។ នេះគឺជាគោលបំណងធំនៃការមកយកកំណើតជាមនុស្ស នៅពេលដែលព្រះយេស៊ូមកផែនដីក្នុងសណ្ឋានជាសាច់ឈាម ។ គ្មាននរណាម្នាក់បានឃើញព្រះនៅក្នុងសណ្ឋានជាព្រះ និង ក្នុងសិរីរុងរឿងរបស់ព្រះអង្គ ទោះដោយប្រើភ្នែកខាងឯរូបកាយ ឬ ប្រើភ្នែកចិត្តនោះឡើយ ។ វិធីដ៏ប្រសើរបំផុតនោះ គឺព្រះអង្គដាក់យើងក្នុងក្រហែងថ្ម ហើយព្រះអង្គយកព្រះហស្តទ្រង់មកបាំងយើងរហូតព្រះអង្គយាងផុត ទើបយើងអាចរស់បាន។ បន្ទាប់មកព្រះអង្គដកព្រះហស្តទ្រង់ចេញ ដូច្នេះទើបអាច" មើល"ព្រះអង្គពីក្រោយបានគឺយើងមិនអាចមើលចំព្រះភក្ត្រទ្រង់បានឡើយ [៦៨] ។ ពីព្រោះព្រះជាម្ចាស់ធំជាងយើងសម្បើមណាស់ គឺព្រះអង្គគង់នៅក្នុងពន្លឺ" ដែលមិនចូលទៅជិតបាន"ដែលគ្មាននរណាម្នាក់អាចមើលឬឃើញព្រះអង្គបានឡើយ[៦៩] ។ ការមកចាប់កំណើតជាមនុស្សគឺជាវិធីសាស្ត្ររបស់ព្រះជាម្ចាស់ក្នុងការប្រាស្រ័យទាក់ទងរបស់ព្រះអង្គផ្ទាល់ដែលលោកអ្នកនិងខ្ញុំអាចយល់បាន ។ "ព្រះជាម្ចាស់គឺជាព្រះតែមួយគត់ដែលគង់នៅក្នុងព្រះឱរានៃព្រះបិតាទ្រង់បានសម្តែងឲ្យស្គាល់ព្រះអង្គ" [៧០] ។

ព្រះយេស៊ូបានមានព្រះបន្ទូលនូវពាក្យស្រដៀងគ្នានេះដែរគឺព្រះអង្គមានព្រះបន្ទូលពីអណ្តូង និង ទឹកជាមួយស្ត្រីនៅក្នុងស្រុក ស៊ូខារ គ្រាប់ពូជស្រង៉ៃ និង ស្រូវជាមួយអ្នកស្តាប់របស់ព្រះអង្គដែលជាកសិករ។ លោកប៉ូលរៀបចំសាររបស់គាត់តាមបែបផ្សេងៗ នៅពេលដែលគាត់និយាយទៅកាន់សាសន៍យូដា និង សាសន៍ក្រេក ដោយនិយាយពាក្យដែលងាយស្រួលឲ្យក្រុម

---

[៦៨] *យ៉ូហាន ១:១៨ ; និក្ខមនំ ៣៣ :២២ -២៣*

[៦៩] *១ ធីម៉ូថេ ៦ :១៦*

[៧០] *យ៉ូហាន ១:១៨ពាក្យដែលថា " សម្តែងឲ្យស្គាល់ " មានន័យថាពន្យល់យ៉ាងច្បាស់ផ្តល់របាយការណ៍យ៉ាងល្អិតល្អន់ ។*

និមួយៗស្តាប់ [៧២] ។ ការនិយាយដោយសុភាពជាមួយមនុស្សគឺជួយភ្ជាប់រាជសាររបស់យើងឲ្យស៊ីគ្នានឹងអ្នកស្តាប់របស់យើង ។

## ការដោះស្រាយជាមួយពួកអ្នកប្រឆាំងជំទាស់

ការធ្វើការដោយប្រើមធ្យោបាយមួយដែលយើងរឹងប៉ឹងសំរាប់សេចក្តីពិត ប៉ុន្តែសុភាពជាមួយសត្រូវរបស់សេចក្តីពិតដែលហាក់ ដូចជាប្រឆាំងទាស់ទទឹង ។ ចំពោះអ្នកមិនជឿហាក់ដូចជាទំនងព្រមទទួលនូវការរឹងមាំចំពោះសេចក្តីពិតរបស់យើងទៅស៊ុមគ្រលំជាអ្នកមិនជឿទៅវិញ។ តើយើងដោះស្រាយចំពោះការទាស់ទទឹងទាំងនេះយ៉ាងណា?

### អ្នកប្រឆាំងនឹងយើងដែលមិនមែនជាគ្រីស្តបរិស័ទ

សាសនាភាគច្រើនជឿថាមានតែពួកគេតែប៉ុណ្ណោះដែលត្រឹមត្រូវ។ សូម្បីតែសាសនាទាំងនោះដូចជាបាហាយ ដែលបាននិយាយថា សាសនាទាំងអស់គឺមានតម្លៃការបដិសេធន៍ចោលមិនព្រមជឿសាសនាណាមួយនោះក៏ជាលក្ខណៈពិសេសណាស់ដែរ ការទទួលយកតែមួយនោះគឺមានសុពលភាពល្អដែរ ។ ការជឿលើព្រះគ្រីស្តតែមួយអង្គនោះនឹងប្រាកដថាមិនអាចគេចផុតពីការប៉ះទង្គិចជាមួយអ្នកដែលមានជំជឿផ្សេងទៀតដែរ ។

នៅពេលដែលការនេះកើតឡើង យើងអាចនឹកឃើញថា យើងមិនចាំបាច់តតាំងយ៉ាងខ្លាំងក្លាជាមួយជំនឿដែលមិនដូចគេក៏ដោយចុះ ។ សាដ្រាក់ មេសាក់ និងអាបេនិកោ នៅតែសម្តែងនៅក្នុងការគោរពរាប់អាន ទោះបីជាគេមិនបានថ្វាយបង្គំរូបសំណាកធ្វើអំពីមាសរបស់ស្តេចនេប៊ូកានេសាក៏ដោយ ។ ពួកគេគ្រាន់តែបង្ហាញពីការគោរពប្តូរផ្តាច់ថ្វាយបង្គំដល់ព្រះយេហូវ៉ា និងមិនព្រមក្រាបបង្គំចំពោះរូបព្រះដទៃណាឡើយ ។ បីជំពូកក្រោយមក នៅក្នុងដានីយ៉ែល

---

[៧២] ចូរប្រៀបធៀបកិច្ចការ១៣:១៤-៤៣ ជាមួយកិច្ចការ១៧:១៦-៣៤

ជំពូក ៣ ដាវីយ៉ូសបានចេញច្បាប់ឲ្យអធិស្ឋានបានតែចំពោះខ្លួនគាត់មួយតែប៉ុណ្ណោះ ។ ដានីយ៉ែលមិនបានចេញប្រតិកម្មតបតមកវិញជាសាធារណៈចំពោះបទបញ្ជានោះឡើយ តែគាត់គ្រាន់តែនៅតែបន្តគោរពប្រតិបត្តិចំពោះជំនឿ របស់គាត់ដោយស្មោះស្ម័គ្រដដែល ។ នៅពេលដែលព្រះតេជគុណភេស្ទុសស្រែកគំហកដាក់ប៉ូលហើយបានចោទប៉ូលថាជាមនុស្សឆ្កួតនោះ លោកប៉ូល មិនបានតបតទៅវិញដោយកំហឹងដែរ ។ គាត់គ្រាន់តែតបថា លោកមានប្រសាសន៍នោះគឺ " ពិតជាត្រឹមត្រូវ និង សមហេតុផលមែន" គឺលោកប៉ូលបានប្រើពាក្យ" ព្រះតេជគុណភេស្ទុស" [៧២] ។ មានការប្រឆាំងច្រើនមែនទែន នៅពេលដែល លោកណាម៉ានដែលបានជាពីជំងឺឃ្លង ហើយបានប្រកាសសុំខមាទោសទុកជាមុននៅពេលដែលគាត់គ្រាន់តែឱនបន្ទាបខ្លួនជាមួយស្តេចនៅក្នុងព្រះវិហារនៃព្រះរីម៉ូន ( តែមិនបានឱនទាំងផ្លូវចិត្តឡើយ ) ហោរាអេលីសេ ( ដែលជាមនុស្សមិនយោគយល់ប៉ុន្មាន ) បែរជាប្រាប់គាត់ថា" សូមអញ្ជើញទៅដោយសុខសាន្តចុះ" [៧៣] ។ ការមិនយល់ព្រមទាំងនេះ គឺគ្មានការជំទាស់ត្រង់ណាដែលមិនអាចធ្វើបាននោះឡើយ គឺអាចធ្វើទៅបាន ។

## អ្នកប្រឆាំងដែលជាគ្រីស្តបរិស័ទ

ផ្ទុយទៅវិញគ្រីស្តបរិស័ទគួរតែជាអ្នកដែលព្រមទទួលនូវការសុភាពទន់ភ្លន់ ដែលធ្វើឲ្យអ្នកផ្សាយដំណឹងល្អអាចមានភាពជិតស្និតទៅនឹងការស្តាប់ដែលមិនទាន់ជឿព្រះរបស់ខ្លួន ពីព្រោះគ្រីស្តបរិស័ទយល់ថាការចូលទៅកៀកជាមួយអ្នកមិនជឿតាមបែបសុភាពទន់ភ្លន់នោះ គេគិតថាជាការស៊ុមគ្រលំ

---

*[៧២] កិច្ចការ ២៦:២៥ នៅក្នុងសម័យគម្ពីរសញ្ញាថ្មី " ព្រះតេជគុណ" គឺជាពាក្យលើកកិត្តិយសដល់អ្នកធ្វើការរាជការ ។ ដើម្បីយកគំរូតាម ប៉ូល គ្រីស្តបរិស័ទសព្វថ្ងៃនេះគួរប្រើពាក្យដែលគួរសមចំពោះអ្នកដែលមិនជឿ ហើយប្រឆាំងយើង ។*

*[៧៣] ពង្សាវតារក្សត្រ ៥:១៥-១៩*

ជាមួយគេធ្វើឲ្យជំនឿគ្រីស្ទបរិស័ទចុះខ្សោយ ។ ពួកអ្នកប្រឆាំងនឹងព្រះយេស៊ូ គេបានចោទព្រះអង្គជារឿយៗថាព្រះអង្គទៅរាប់អានជាមួយពួកអ្នកទារពន្ធនិង ពួកមនុស្សមានបាបដោយភ្លេចគិតថា ពួកអ្នកទាំងនោះហើយជាអ្នកឈឺដែល ត្រូវការគ្រូពេទ្យ[៧៤] និងខកខានមិនបានយល់ពីជម្រៅនៃសេចក្ដីស្រលាញ់របស់ ព្រះជាម្ចាស់ដែលព្រះមានសំរាប់ពួកមនុស្សបាត់បង់ និង មិនដឹងពីជម្រៅ ព្រះហឫទ័យដែលចង់បានឲ្យគេបានវិលត្រលប់ជឿព្រះអង្គវិញខ្លាំងប៉ុណ្ណា នោះឡើយ[៧៥] ។ គ្រីស្ទបរិស័ទសាសន៍យូដាបានរិះគន់ដល់លោកពេត្រុស ចំពោះការដែលគាត់ទៅបរិភោគជាមួយពួកមិនកាត់ស្បែក ។ លោកសាវ័កត្រូវ ពន្យល់ឲ្យបានក្បោះក្បាយដល់ពួកគេចំពោះការច្បាស់លាស់នៃការដែលព្រះ ត្រាស់ហៅគាត់ឲ្យទៅសួរសុខទុក្ខដល់កូនីលាស និង ក្រោយមកកូនីលាស បាន កែប្រែចិត្តទទួលជឿដល់ព្រះ[៧៦] ។ ដូច្នេះវាមិនមែនជារឿងប្លែកឡើយដែល គ្រីស្ទបរិស័ទសព្វថ្ងៃនេះបានរិះគន់អ្នកខ្លះទៀត ដែលបានទៅប្រកបជិតស្និត ជាមួយអ្នកដែលមានជំនឿខុសប្លែកពីខ្លួននៅក្នុងខណៈដែលពួកគេបានព្យាយាម ផ្សាយដំណឹងល្អដល់ពួកនោះ ។

នៅពេលដែលរឿងនេះបានកើតឡើងភាគីនិមួយៗត្រូវគិតពីគំនិត ល្អនៃភាគីម្ខាងទៀត គឺត្រូវចងចាំថារឿងនេះអាចមានទំនាស់នឹងគ្នា ដូចជា រឿងរ៉ាវ ដទៃទៀតដែរ គឺថាគ្រីស្ទបរិស័ទមានជំនឿល្អតែគ្រាន់តែមានជំហរផ្សេងពីគ្នា ប៉ុណ្ណោះ។ ដរាបណាមើលឃើញច្បាស់ថា អ្នកនោះទៅស៊ុមគ្រលំជាមួយនឹង ជំនឿដទៃ ឬ មានអំពើបាបនិងប្រាសចាកពីព្រះគម្ពីរ បើពុំដូច្នោះទេ គ្រីស្ទបរិស័ទ

---

*[៧៤] ម៉ាថាយ ៩:១០-១៣*

*[៧៥] លូកា ១៥:១-២ និងរឿងប្រៀបប្រដូចទាំងបីដូចតទៅ ។*

*[៧៦] កិច្ចការ ១១:១-១៨ រឿងនេះត្រូវបានគេនិយាយប្រាប់ពីរដងពីព្រោះវា មិនមែនជាការងាយស្រួលចំពោះគ្រីស្ទបរិស័ទជនជាតិយូដាទៅ ដើម្បីសតវត្សរ៍ទីមួយ ឲ្យជឿថាព្រះពិតជាស្រឡាញ់និងព្រមទទួលសាសន៍ដទៃនោះ ។*

មិនត្រូវស្អប់ ឬ ប្រកាន់ទៅដល់គ្នាទៅវិញទៅមកចំពោះអ្នកដែលមិនបានប្រព្រឹត្ត ដូចខ្លួនទាំងស្រុងនោះ ។ ម្នាក់ៗត្រូវតែឈរឆ្លើយដោះសាចំពោះអ្វីដែលខ្លួនបាន ធ្វើដោយខ្លួនឯងចំពោះព្រះគឺមិនមែនឆ្លើយចោទប្រកាន់អ្នកដទៃនោះទេ [៧៧] ។

## សរុបសេចក្តី

សុភាពទន់ភ្លន់តែមិនរឹងមាំគឺនាំឲ្យយើងបាត់បង់នូវភាពច្បាស់លាស់ ពីរាជសារដែលយើងត្រូវផ្សាយ ។ រឹងប៉ឹង តែមិនមានភាពទន់ភ្លន់ធ្វើឲ្យមាន រនាំងបាំងយើងខណ្ឌដាច់ចេញពីចិត្តនៃអ្នកស្តាប់របស់យើង ។ ព័ន្ធកិរិដែលយក គំរូតាមព្រះគម្ពីរ ដែលមានប្រសិទ្ធិភាពគឺប្រើទាំងពីររឹងមាំ ចំពោះការស្វែងយល់ពី សេចក្តីពិតការសម្រេចចិត្ត និង ការប្រព្រឹត្តិអ្វីដែលទាក់ទងទៅនឹងសេចក្តីពិត តែសុភាពទន់ភ្លន់ពេលទាក់ទងនឹងការញែកដាច់ដោយឡែក ការស្តាប់និងការ យកលំនាំតាមអ្វីមួយដើម្បីឲ្យងាយស្រួលក្នុងការផ្សាយពីសេចក្តីពិតដល់ មនុស្សផងទាំងពួង ។

---

[៧៧] រ៉ូម ១៤:១-១៥:៤